សាលាបឋមសិក្សា សោថហ្វ៊ក (Southwark)

## **ក្រមសីលធម៌សម្រាប់បច្ចេកវិទ្យាផ្នែកកុំព្យូទ័រ**

១. សិស្សានុសិស្សទាំងអស់ត្រូវតែ**ស្លៀកពាក់ឲ្យបានសមរម្យ**សម្រាប់សាលា ដូចបានរៀបរាប់នៅក្នុងវិន័យនៃការស្លៀកពាក់របស់សាលាបឋមសិក្សា សោថហ្វ៊ក។

២. មិនអនុញ្ញាតឲ្យសិស្សយក ចំណីអាហារ ស្ករគ្រាប់ ស្ករកៅស៊ូ ឬភេសជ្ជៈ ចូលក្នុងបន្ទប់កុំព្យូទ័រជាដាច់ខាត។

៣. សិស្សអាចញ៉ាំទឹកនៅ ទីមានទឹកបាញ់សម្រាប់ផឹក (water fountain) ឬទៅបន្ទប់ទឹកមុនពេលចូលក្នុងបន្ទប់កុំព្យូទ័រ។ មិនអនុញ្ញាតឲ្យសិស្សចេញពីបន្ទប់កុំព្យូទ័រក្នុងម៉ោងរៀនទេ លើកលែងតែពេលមានអាសន្ន។

៤. សិស្សត្រូវ **ចូល** **និង** **ចេញ** ពីបន្ទប់កុំព្យូទ័រដោយ **ដើរជាពីរជួរ ដោយមានសណ្តាប់ធ្នាប់**។

៥. សិស្សត្រូវអង្គុយនៅមុខកុំព្យូទ័រដែលគេបានចាត់ឲ្យ នៅពេលគេប្រាប់ឲ្យធ្វើដូច្នេះ។ សិស្សដែលមិនអង្គុយនៅមុខកុំព្យូទ័រដែលគេបានចាត់ឲ្យនៅម៉ោងរៀន នឹងមិនទទួលពិន្ទុឡើងថ្នាក់សម្រាប់ថ្នាក់នោះទេ ទោះជាបានប្រគល់កិច្ចការឲ្យគ្រូវិញក៏ដោយ។

៦. សិស្សត្រូវធ្វើគ្រប់កិច្ចការ**ទាំងអស់** ដែលគេបានចាត់ឲ្យធ្វើ។ គេមិនទទួលយកកិច្ចការណាដែលប្រគល់ឲ្យយឺតពេលទេ លើកលែងតែសិស្សបានពិភាក្សាអំពីរឿងនេះជាមួយគ្រូបង្រៀនកុំព្យូទ័រ។ កិច្ចការដែលឲ្យយឺតពេលនឹងបានពិន្ទុទាប បើសិនជាគ្រូសុខចិត្តទទួលយកកិច្ចការនោះ។

៧. សិស្សមិនអាចយកគ្រឿងអេឡិចត្រូនិចផ្សេងៗ (ដូចជា **ទូរស័ព្ទដៃ អាយផត ប្រដាប់ចុចលេងល្បែង**) ទៅក្នុងបន្ទប់កុំព្យូទ័របានទេ។ បើសិនជាគេឃើញសិស្សប្រើរបស់ទាំងនេះ គេនឹងដកហូតរបស់ទាំងនេះទុក រហូតដល់ម៉ោងចេញទៅផ្ទះវិញ - បើសិស្សប្រើរបស់ទាំងនេះម្តងហើយម្តងទៀតនៅក្នុងម៉ោងរៀន នឹងបណ្តាលឲ្យគេដកហូតរបស់ទាំងនេះទុក ហើយគេនឹងប្រគល់របស់ទាំងនេះឲ្យទៅ **តែឪពុកម្តាយ** របស់សិស្សតែប៉ុណ្ណោះ។

៨. សិស្ស**មិនអាចថតចម្លង (print) អ្វីមួយបានទេ** លើកលែងតែគ្រូប្រាប់ ឬអនុញ្ញាត ឲ្យធ្វើ។

៩. នៅពេលចប់ថ្នាក់រៀន សិស្សត្រូវ ចុចបិទឈ្មោះប្រើរបស់ខ្លួន (LOG OFF) ពីកុំព្យូទ័រ នៅពេលណាគេប្រាប់ឲ្យចុចបិទ។ បន្ទាប់មក ពួកគេត្រូវដាក់អ្វីៗដែលបានធ្វើរួចទាំងអស់ ទៅក្នុងក្របដាក់ក្រដាសស្នាមសម្រាប់ថ្នាក់របស់ពួកគេ ហើយឈរតម្រង់ជាពីរជួរ ដោយមានសណ្តាប់ធ្នាប់ មុនពេលគ្រូប្រចាំថ្នាក់របស់ពួកគេ នាំពួកគេចេញពីបន្ទប់កុំព្យូទ័រ។

ហត្ថលេខារបស់សិស្ស៖ ________________________________________________ ថ្ងៃខែ៖ _______________

ហត្ថលេខារបស់មាតាបិតា ឬអាណាព្យាបាល៖ _________________________________ ថ្ងៃខែ៖ _______________

ដើម្បីជ្រាបពីឯកសារដែលបានបកប្រែ និងព័ត៌មានបន្ថែមជាភាសាខ្មែរ សូមមើលក្នុងវិបសៃ៖ www.philasd.org/language/khmer